គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សា រកធាតុចូលដើម្បីលើកគម្រោងរបស់ប្រទេសកាណាដា ក្រោមមូលនិធិ អាស៊ាន-កាណាដា សម្រាប់គំនិតផ្តួចផ្តើមថ្នាក់មូលដ្ឋាន ឆ្នាំ២០២០-២០២១

ថ្ងៃអង្គារ ៨កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបបួន ត្រូវនឹងថ្ងៃទីសាមសិប ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោង៨បួន និងសាមសិបនាទី រសៀល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សា រកធាតុចូលដើម្បីលើកគម្រោងរបស់ប្រទេសកាណាដា ក្រោមមូលនិធិអាស៊ាន-កាណាដា សម្រាប់គំនិតផ្តួចផ្តើមថ្នាក់មូលដ្ឋាន ឆ្នាំ២០២០-២០២១ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង អស់លោក ប្រធានក្រុមជំនួយកិច្ចការទាំង៦ និងមន្ត្រីពាក់ព័ន្ធមួយចំនួន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងកិច្ចប្រជុំនាពេលនេះ ។ **លោកជំទាវ** លើកឡើងអំពី ខ្លឹមសារ នៃលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លេខ ៤០៣៤ ជស/អស៊/កបទ.សអ ផ្ញើជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ស្តីពី សេចក្តីប្រកាសរបស់ប្រទេស កាណាដាទទួលសំណើគម្រោងរបស់អាស៊ាន ក្រោមមូលនិធិ អាស៊ាន-កាណាដា សម្រាប់គំនិតផ្តួចផ្តើមថ្នាក់ មូលដ្ឋាន ឆ្នាំ២០២០-២០២១ ដែលការលើកគម្រោងសុំប្រើប្រាស់មូលនិធិ នេះមានលក្ខខណ្ឌចំនួន ០៣ ៖

១.ស្ថាប័នស្នើសុំប្រើប្រាស់មូលនិធិនេះ អាចជាក្រសួង/ស្ថាប័នថ្នាក់ជាតិ អង្គការសង្គមស៊ីវិល ឬអង្គការក្រៅ រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលធ្វើការពាក់ព័ន្ធនឹងថ្នាក់មូលដ្ឋាន ។

២.ត្រូវមានការចូលរួម ឬពាក់ព័ន្ធពីប្រទេសសមាជិកអាស៊ាន យ៉ាងតិចចំនួន០៣ ឬអាចស្នើសុំជាបុគ្គល ប៉ុន្តែគោលដៅ នៃគម្រោងគឺ ត្រូវផ្តល់ប្រយោជន៍ដល់ប្រទេសសមាជិកអាស៊ាន យ៉ាងតិចចំនួន ០៣ ។

៣.ផ្តោតលើវិស័យផ្សេងៗ ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់អាស៊ាន ដូចជា សមភាពយេនឌ័រ សន្តិភាព សន្តិសុខ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ជាដើម ។

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មានប្រសាសន៍លើកឡើងអំពីសកម្មភាពការងារបន្ទាន់មួយ ចំនួនដើម្បីឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ដូចជាការផ្តល់ជូនដូចជាសម្ភារៈប្រើប្រាស់ ស្បៀងអាហារ ជូនដល់ប្រជា ពលរដ្ឋក្រីក្រ ជនងាយរងគ្រោះ ស្ត្រីភេទ កុមារ និងពលករដែលត្រឡប់មកពីប្រទេសថៃក្នុងពេលវិបត្តិកូវីដ-១៩ ។ **លោកជំទាវ** លើកឡើងអំពីការព្រួយបារម្ភអំពីរលកទី២ នៃកូវីដ-១៩ កើតឡើងម្តងទៀត ដែលប្រជាពលរដ្ឋហាក់ ដូចជាមើលស្រាល ព្រងើយកន្តើយក្នុងការយកចិត្តទុកដាក់រក្សាអនាម័យ ការប្រាស្រ័យទាក់ទង ការជួបជុំ បន្ទាប់ពី មានភាពស្ងប់ស្ងាត់ នៃជំងឺកូវីដ-១៩ កន្លងមក ។ **លោកជំទាវ** មានប្រសាសន៍អំពីការងារសាងសង់មណ្ឌលសំចត

តាមច្រកទ្វារព្រំដែន នៃបណ្តាខេត្តជាប់ព្រំដែន ក្នុងគោលបំណងជួយសម្រួលដល់ជនរងគ្រោះដោយការបញ្ជូនត្រឡប់របស់អាជ្ញាធរថៃ ឬដោយប្រការណាមួយ ដែលអាចឲ្យពលករសម្រាក សាកសួរព័ត៌មាន និងជាមណ្ឌលចត្តាឡីស័កក្នុងការតាមដានរកអ្នកឆ្លងជំងឺកូវីដ-១៩ បានផងដែរ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម ទិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ បានលើកឡើងការព្រួយបារម្ភអំពីជំងឺកូវីដ-១៩ នេះផងដែរ និងបានលើកពីអំពើយុបឃិតរវាងមន្ត្រីគ្រប់គ្រងមណ្ឌលចត្តាឡីស័ក និងអ្នកដំណើរ ឬប្រជាពលរដ្ឋដែលទើបមកពីក្រៅប្រទេស ដោយគ្រាន់តែចំណាយលុយទៅលើមន្ត្រីគ្រប់គ្រង គឺបានត្រឡប់មកផ្ទះជួបជុំគ្រួសារ ឬប្រកបការងារ មុខរបរ ជំនួញផ្សេងៗបាន ដែលបញ្ហាទាំងអស់នេះយើងត្រូវតែរួមគ្នាគិត និងប្រុងប្រយ័ត្នបំផុត ។ **ឯកឧត្តម** បានលើកបន្ថែមអំពីការជួបជុំគ្នា និងគម្លាតសង្គមហាក់ដូចជាលែងអនុវត្តដូចមុន និងមានការបើកភោជនីយដ្ឋាន កន្លែងផឹកស៊ីមួយចំនួន និងកន្លែងស្ទីម សោនាជាដើម ដែលអាចនឹងកើតមាននូវរលកទី២ នៃជំងឺកូវីដ-១៩ បាន ។

សរុបមក **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានស្នើដល់ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការទាំង៦ ៖

- រកជាតុចូលដើម្បីលើកគម្រោងរបស់ប្រទេសកាណាដាទទួលសំណើគម្រោងរបស់អាស៊ាន ក្រោមមូលនិធិអាស៊ាន-កាណាដា សម្រាប់គំនិតផ្តួចផ្តើមថ្នាក់មូលដ្ឋាន ឆ្នាំ២០២០-២០២១ ដែលគម្រោងនេះទាក់ទងនឹងការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- បន្តតាមដានការងារការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍មិនប្រក្រតី ។
- ត្រៀមរបាយការណ៍៦ខែ ដើម្បីឆ្លងក្រសួង ស្ថាប័នពាក់ព័ន្ធ ។
- ត្រៀមកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ ៣ខែ ម្តង ។
- លេខាធិការដ្ឋាន ក្រុមការងារទាំង៦ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ត្រូវធ្វើការវិភាគមុខងារ ក្របខណ្ឌតួនាទី ភារកិច្ច ទៅតាមរចនាសម្ព័ន្ធរបស់ខ្លួន ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំមួយ និងសាមសិបនាទី ថ្ងៃខែឆ្នាំដដែល ។៚

ថ្ងៃព្រហ ១៣ កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០២០
**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ. សៅ ស៊ីនួន

បានឃើញ
15/07/2020

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់
ថ្ងៃអង្គារ ៩ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២០
**អគ្គលេខាធិការ គ.ជ.ប.ជ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ិណ សំខាន់